# មេរៀនទី ២: ទំនាយសាការីអំពីព្រះយេស៊ូវ

## លូកា ១:៦៨-៧៩

**គោលបំណង៖** ព្រះតែងតែបំពេញតាមតម្រូវការរបស់យើង។

**ខគម្ពីរចងចាំ៖ យ៉ូហាន ៣:១៧** *“ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ឲ្យមកក្នុងលោកីយ៍ ដើម្បីនឹងជំនុំជំរះលោកីយ៍នោះទេ គឺឲ្យលោកីយ៍បានសង្គ្រោះដោយសារទ្រង់វិញ។”*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ដូចទំនាយដែលសាការីបានទាយ យ៉ូហានបាទីស្ទបានរៀបចំផ្លូវសម្រាប់ព្រះមេស្ស៊ីដែលនឹងយាងមក ដោយសារទំនាក់ទំនងរបស់យើងជាមួយព្រះយេស៊ូវ យើងក៏មានទំនួលខុសត្រូវក្នុងការរៀបចំអ្នកដទៃឱ្យយល់ និងទទួលយកព្រះយេស៊ូវដែរ។ ក្នុងនាមជាគ្រូបង្រៀនសាលាថ្ងៃអាទិត្យ អ្នកកំពុងធ្វើជាយ៉ូហានបាទីស្ទសម្រាប់កុមារ។ វាជាទំនួលខុសត្រូវរបស់អ្នកក្នុងការរៀបចំចិត្តរបស់កុមារឱ្យយល់ និងទទួលយកព្រះយេស៊ូវ។ សូមអធិស្ឋានសម្រាប់ខ្លួនអ្នកក៏ដូចជាកុមារ នៅពេលដែលអ្នកត្រៀមខ្លួនក្នុងការបង្រៀននៅថ្ងៃអាទិត្យនេះ។

**ចំរៀង៖** ១. អបអរសាទរ ២. ណូអែលឆ្នាំនេះ ៣. ជូនពរណូអែល ៤. ថ្ងៃសប្បាយរីករាយ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ៣. ល្បែងកំសាន្ត «ការបញ្ចេញទឹកមុខ»



តើអ្នកធ្វើទឹកមុខដូចម្តេចនៅពេលអ្នកមានអារម្មណ៍ខុសឆ្គង?
តើអ្នកធ្វើទឹកមុខដូចម្តេចពេលអ្នកសប្បាយចិត្ត? តើអ្នកធ្វើទឹកមុខដូចម្តេចពេលអ្នកខឹង?
តើអ្នកធ្វើទឹកមុខដូចម្តេចពេលអ្នកពិបាកចិត្ត?
តើអ្នកធ្វើទឹកមុខដូចម្តេចនៅពេលដែលឪពុកម្តាយអ្នកឱបអ្នក?
តើអ្នកធ្វើទឹកមុខដូចម្តេចនៅពេលអ្នកមានអារម្មណ៍សន្តិភាព?
តើអ្នកធ្វើទឹកមុខដូចម្តេចនៅពេលដែលព្រះឆ្លើយនឹងការអធិស្ឋានរបស់អ្នក?
តើអ្នកធ្វើទឹកមុខដូចម្តេចនៅពេលដែលព្រះបំពេញតម្រូវការរបស់អ្នក?
ព្រះតែងតែចង់បំពេញតម្រូវការរបស់យើង។ ថ្ងៃនេះយើងនឹងរៀនអំពីតម្រូវការដ៏ធំបំផុតដែលយើងមាន និងរបៀបដែលព្រះបានយកចិត្តទុកដាក់ដើម្បីបំពេញតម្រូវការរបស់យើង។

## ៤. ការណែនាំមេរៀន

តម្រូវការដ៏ធំបំផុតរបស់យើងក្នុងនាមជាមនុស្សគឺ ដើម្បីជួសជុលទំនាក់ទំនងខូចខាតរបស់យើងជាមួយព្រះ។ នៅពេលដែលអ័ដាម និងអេវ៉ាបរិភោគផ្លែឈើដឹងខុសត្រូវ ទំនាក់ទំនងរបស់យើងជាមួយព្រះត្រូវបានបែកបាក់

ដោយព្រោះតែអំពើបាប។ មនុស្សបានធ្វើការជ្រើសរើសដើម្បីបដិសេធព្រះ ហើយលែងទទួលយកសេចក្តីស្រលាញ់របស់យើងជាមួយទ្រង់។ ប៉ុន្តែព្រះចង់ផ្តល់ឱ្យយើងនូវឱកាសទីពីរក្នុងការជ្រើសរើសទ្រង់ ដើម្បីឲ្យយើងរួចចេញពីអំពើបាប។ ព្រះបានដឹងថាយើងត្រូវការព្រះគុណ និងសេចក្តីមេត្តាករុណារបស់ព្រះដើម្បីត្រលប់មករកទ្រង់វិញ។ តើព្រះបានប្រទាននូវឱកាសទីពីរដល់យើងយ៉ាងដូចម្តេច?

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ជាយូរណាស់មកហើយហោរាម្នាក់ឈ្មោះសាការីបានប្រាប់មនុស្សគ្រប់គ្នាថា ព្រះអង្គសង្គ្រោះនឹងយាងមកក្នុងពេលឆាប់ៗនេះ។ ព្រះអង្គសង្គ្រោះគឺជាអ្នកដែលជួយយើងក្នុងការឡើងទៅស្ថានសួគ៌។ សាការីមិនដឹងឈ្មោះរបស់ព្រះអង្គសង្គ្រោះទេព្រោះទ្រង់មិនទាន់កើត។ ប៉ុន្តែយើងស្គាល់ព្រះនាមរបស់ព្រះអង្គសង្គ្រោះ។ តើនរណាជាព្រះអង្គសង្គ្រោះ? ព្រះយេស៊ូវគឺជាព្រះអង្គសង្គ្រោះ!

សាការីគឺជាបុរសដែលមានវ័យចំណាស់ប៉ុន្តែគាត់មិនមានកូនទេ។ ទេវតាមួយបានមកហើយសន្យានឹងសាការីថាគាត់នឹងមានកូនប្រុសម្នាក់ ហើយកូនប្រុសរបស់គាត់នឹងរៀបចំផ្លូវសម្រាប់ព្រះអម្ចាស់។ សាការីមិនអាចជឿថាគាត់អាចមានកូននៅពេលគាត់ចាស់ឡើយ។ ប៉ុន្តែព្រះតែងតែដឹងនូវអ្វីដែលយើងត្រូវការ និងបំពេញតាមតម្រូវការរបស់យើង។ ប្រពន្ធរបស់គាត់ឈ្មោះអេលីសាបិតមានផ្ទៃពោះនៅពេលនាងមានវ័យចំណាស់ ហើយគាត់ក៏សម្រាលបានកូនប្រុសម្នាក់។ កូនប្រុសរបស់គាត់ឈ្មោះថាយ៉ូហានបាទីស្ទ។ សាការីដឹងថា កូនប្រុសរបស់គាត់នឹងធំឡើង ដើម្បីរៀបចំផ្លូវថ្វាយព្រះអង្គសង្គ្រោះ។

ព្រះបានដឹងថាពិភពលោកនេះត្រូវការព្រះអង្គសង្គ្រោះ។ យើងទាំងអស់គ្នាបានធ្វើខុស។ យើងទាំងអស់គ្នាត្រូវការជំនួយដើម្បីត្រលប់ទៅរកព្រះវិញ។ ព្រះអង្គសង្គ្រោះនឹងអភ័យទោសឱ្យយើងហើយនាំយើងត្រលប់ទៅរកព្រះវិញ។ ព្រះអង្គសព្វព្រះហឫទ័យក្នុងការបំពេញតម្រូវការរបស់យើង! យើងត្រូវការជំនួយពីព្រះ។ ទ្រង់តែងតែបំពេញតម្រូវការរបស់យើងហើយជួយយើង!

## ៦. សំនួរពិភាក្សា

១. តើសាការីមិនមានអ្វីនៅពេលដែលគាត់ចាស់ណាស់ទៅហើយ? *គាត់មិនមានកូនប្រុសទេ*

២. តើកូនប្រុសរបស់គាត់ឈ្មោះអ្វី? *យ៉ូហានបាទីស្ទ*

៣. តើសាការីគិតថាយ៉ូហានបាទីស្ទនឹងធ្វើអ្វីដល់ព្រះអង្គសង្គ្រោះ? *រៀបចំផ្លូវថ្វាយព្រះអម្ចាស់*

៤.តម្រូវការដ៏ធំបំផុតរបស់យើងគឺការអភ័យទោសចំពោះអំពើបាបរបស់យើង។ តើអ្នកណាអាចអត់ទោសឱ្យយើងបាន? *ព្រះ / ព្រះយេស៊ូវ*

## ៧. ល្បែងកំសាន្ត « ត្រាប់តាម »

១. **របៀបលេង៖** គឺឲ្យកុមារម្នាក់ដែលជាអ្នកចាំទីទៅខាងក្រៅថ្នាក់រៀន

២. ហើយឲ្យកុមារទាំងអស់ដែលនៅក្នុងថ្នាក់អង្គុយជារង្វង់

៣. បន្ទាប់មកជ្រើសរើសកុមារម្នាក់ឲ្យធ្វើជាអ្នកនាំកាយវិការ

៤. កុមារផ្សេងទៀតត្រូវធ្វើតាមអ្នកនាំកាយវិកានោះ (ឧ. អេះក្បាល ទាញត្រចៀក អេះដៃ អេះគូទ...)

៥. បន្ទាប់ពីរួចរាល់ត្រូវហៅអ្នកចាំទីមកទាយថា អ្នកណាជាអ្នកនាំកាយវិកា បើគាត់ទាយខុសគាត់ត្រូវទៅចាំទីម្តងទៀត បើគាត់ទាយត្រូវ អ្នកនាំកាយវិការត្រូវទៅចាំទីម្តង។

**៨. ខគម្ពីរចងចាំ** **យ៉ូហាន ៣:១៧**

**៩. ហាត្ថកម្ម** **«តើអ្នកត្រូវការអ្វី? »**

**សម្ភារៈដែលត្រូវការៈ** សូមបោះពុម្ពគ្រឿងតុបតែងនៅថ្ងៃបុណ្យណូអែល(សូមមើលនៅខាងក្រោម)



សូមផ្តល់នូវគ្រឿងតុបតែងថ្ងៃបុណ្យណូអែលមួយឬពីរសំរាប់សិស្សម្នាក់ៗ ហើយសុំឱ្យពួកគេសរសេរពីតម្រូវការរបស់ពួកគេ។ ប្រហែលជាពួកគេត្រូវការសន្តិភាព សុភមង្គល ការលួងលោម លុយកាក់ ម្ហូបអាហារ។ ល។ ពួកគេអាចសរសេរអ្វីដែលពួកគេត្រូវការនិងផាត់ពណ៌។ ប្រើគ្រឿងតុបតែងដើម្បីតុបតែងដើមគ្រីស្ទម៉ាសកាលពីសប្តាហ៍មុន។ (ប្រសិនបើអ្នកមិនបានធ្វើដើមឈើគ្រីស្ទម៉ាស ពីមេរៀនកាលពីសប្តាហ៍មុនទេនោះកុមារអាចតុបតែងជញ្ជាំងដោយគ្រឿងតុបតែងរបស់ពួកគេ)។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*











